ប្រការ ១២.–

សមាសភាពគណៈកម្មការសហគមន៍នេសាទរួមមាន ប្រធាន អនុប្រធាន និងសមាជិក។ គណៈកម្មការសហគមន៍នេសាទ ត្រូវបោះឆ្នោតជ្រើសរើសសមាជិកទទួលបន្ទុកលេខាធិការមួយរូប និងសមាជិកទទួលបន្ទុកហិរញ្ញិកមួយរូប និងត្រូវពិភាក្សាបែងចែកភារកិច្ចសមាជិកផ្សេងទៀតតាមការជាក់ស្តែង។

ប្រធានគណៈកម្មការសហគមន៍នេសាទទទួលខុសត្រូវដឹកនាំ និង គ្រប់គ្រងសហគមន៍នេសាទទាំងមូល ។
អនុប្រធានគណៈកម្មការសហគមន៍នេសាទជាជំនួយការឱ្យប្រធាន ។

**ប្រការ ១៣.–**

គណៈកម្មការសហគមន៍នេសាទមានអាណត្តិប្រាំ(៥) ឆ្នាំ ចាប់ពីថ្ងៃបោះឆ្នោត ហើយផុតកំណត់នៅពេលដែលមានគណៈកម្មការសហគមន៍នេសាទថ្មីដែលត្រូវបានបោះឆ្នោតជ្រើសរើសក្នុងមហាសន្និបាតឱ្យចូលកាន់តំណែងជំនួស ។ ក្នុងករណីដែលសហគមន៍នេសាទដំណើរការមិនប្រក្រតី ដោយមូលហេតុដំណើរការមិនល្អ ឬ អសមត្ថភាពក្នុងការគ្រប់គ្រងសហគមន៍នេសាទ សមាជិកសហគមន៍នេសាទចំនួនមួយភាគបី(១/៣) មានសិទ្ធិស្នើសុំបើកមហាសន្និបាតវិសាមញ្ញ ដើម្បីបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទជាថ្មី ។

**ប្រការ ១៤.–**

ក្នុងករណីដែលសមាជិកគណៈកម្មការសហគមន៍នេសាទណាម្នាក់អវត្តមាន ដោយគ្មានមូលហេតុរយៈពេលប្រាំមួយ(៦) ខែ ឬសុំលាលែងមុនចប់អាណត្តិ បេក្ខជនដែលមានឈ្មោះតាមសំឡេងគាំទ្របន្ទាប់ក្នុងពេលបោះឆ្នោតជ្រើសរើសក្នុងមហាសន្និបាតកន្លងមក ត្រូវបានជ្រើសតាំងជំនួស ។

## ជំពូកទី ៦

## របៀបរបបប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ

**ប្រការ ១៥.–**

គណៈកម្មការសហគមន៍នេសាទត្រូវកំណត់របបប្រជុំឱ្យបានទៀងទាត់រៀងរាល់ខែ ។ កិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទអាចប្រព្រឹត្តទៅបាន លុះត្រាតែមានសមាជិកគណៈកម្មការចូលរួមយ៉ាងតិចចំនួន ២/៣ (ពីរភាគបី) នៃសមាជិករបស់គណៈកម្មការសហគមន៍នេសាទទាំងមូល ។

**ប្រការ ១៦.–**

ប្រធានគណៈកម្មការសហគមន៍នេសាទជាអ្នកកោះអញ្ជើញ និង ធ្វើជាប្រធានគ្រប់កិច្ចប្រជុំ ។ ក្នុងករណីប្រធានគណៈកម្មការសហគមន៍នេសាទអវត្តមាន អនុប្រធានដែលត្រូវបានប្រគល់សិទ្ធិត្រូវធ្វើជាប្រធានអង្គប្រជុំ ។ រាល់ការប្រជុំត្រូវមានកំណត់ហេតុ និងបញ្ជីវត្តមានច្បាស់លាស់ ។

ប្រធានអង្គប្រជុំត្រូវធានាឱ្យគ្រប់កិច្ចប្រជុំសហគមន៍នេសាទប្រព្រឹត្តទៅដោយលក្ខណៈប្រជាធិបតេយ្យមានរបៀបរៀបរយ និងគ្មានការរំខាន ។

ប្រធានអង្គប្រជុំ អាចបណ្តេញសមាជិកអង្គប្រជុំណាម្នាក់ចេញពីកិច្ចប្រជុំបាន ក្នុងករណីដែលសមាជិកនោះធ្វើឱ្យខូចសណ្តាប់ធ្នាប់អង្គប្រជុំ ។

មាត្រា ១៧ .–

ការសម្រេចលើបញ្ហាណាមួយរបស់សហគមន៍ដូចមានចែងខាងក្រោមនេះ គឺត្រូវអនុម័តដោយកិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទដោយមានសំឡេងគាំទ្រយ៉ាងតិចលើសពីពាក់កណ្តាល នៃចំនួនសមាជិកគណៈកម្មការសហគមន៍នេសាទដែលមានវត្តមានក្នុងអង្គប្រជុំ។ ក្នុងករណីដែលមានសំលេងស្មើគ្នា មតិប្រធានអង្គប្រជុំជាឧត្តមានុភាព ÷

- សេចក្តីព្រាងកិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- សេចក្តីព្រាងគម្រោងថវិកា ចំណូល និងចំណាយក្នុងសហគមន៍នេសាទ
- ការព្យួរសមាជិកភាពរបស់សមាជិកដែលមានកំហុស
- ការទទួលពាក្យសុំចូលជាសមាជិកថ្មី
- ការដាក់ទណ្ឌកម្មតាមបទបញ្ជាផ្ទៃក្នុង ដល់សមាជិកសហគមន៍នេសាទ។

បន្ទាប់ពីកិច្ចប្រជុំចប់ភ្លាមប្រធានគណៈកម្មការសហគមន៍នេសាទ ត្រូវចាត់ឱ្យធ្វើការជូនដំណឹងដល់សមាជិកសហគមន៍នេសាទអំពីសេចក្តីសម្រេចរបស់ខ្លួន។ សេចក្តីសម្រេចនៃអង្គប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការសហគមន៍នេសាទ ឬសាលាឃុំក្នុងរយៈពេល ៧ ថ្ងៃយ៉ាងយូរបន្ទាប់ពីការប្រជុំ។

## ជំពូកទី ៧

## មហាសន្និបាតសហគមន៍នេសាទ

មាត្រា ១៨.–

មហាសន្និបាតសហគមន៍នេសាទជាអង្គប្រជុំកំពូល ដើម្បីធ្វើការអនុម័ត និងធ្វើសេចក្តីសម្រេចទាំងឡាយក្នុងនាមសហគមន៍នេសាទ។ មហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ ត្រូវប្រារព្ធធ្វើឡើង បន្ទាប់ពីក្រុមស្ថាបនិកបានរៀបចំរាល់នូវកិច្ចការទាំងឡាយដែលពាក់ព័ន្ធនឹងដំណើរការមហាសន្និបាត។

ការកោះប្រជុំមហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ ធ្វើឡើងដោយក្រុមប្រឹក្សាឃុំ ដោយមានការជួយសម្របសម្រួលពីសមត្ថកិច្ចរដ្ឋបាលជលផល តាមការស្នើសុំរបស់ក្រុមស្ថាបនិក ហើយត្រូវមានការចូលរួមពីសមាជិកដែលបានដាក់ពាក្យស្នើសុំរួចមកហើយ។

មហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ អនុម័តនូវសេចក្តីសម្រេច និងកិច្ចការសំខាន់ដូចខាងក្រោម ÷

- អ្នកដែលដាក់ពាក្យសុំចូលជាសមាជិកសហគមន៍នេសាទ
- ឈ្មោះសហគមន៍នេសាទ
- លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ
- ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ។

ប្រការ ១៩.–

មហាសន្និបាតសាមញ្ញត្រូវរៀបចំឡើង១ឆ្នាំម្តង ដើម្បីសរុបលទ្ធផលការងារប្រចាំឆ្នាំនិងអនុម័តនូវកិច្ចការសំខាន់ៗរបស់សហគមន៍នេសាទ។ ក្នុងករណីចាំបាច់សហគមន៍អាចរៀបចំមហាសន្និបាតវិសាមញ្ញតាមការស្នើសុំពីសមាជិកសហគមន៍នេសាទចំនួនមួយភាគបី (១/៣) យ៉ាងតិច។

ប្រការ ២០.–

គណៈកម្មការសហគមន៍នេសាទអាចអញ្ជើញរដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋាន ឬក្រុមប្រឹក្សាឃុំ សមត្ថកិច្ចពាក់ព័ន្ធ ឬអ្នកគាំទ្រចូលរួមសង្កេតការណ៍ ឬសម្របសម្រួល ឬជាកិត្តិយសក្នុងមហាសន្និបាតសហគមន៍នេសាទ។

ប្រការ ២១.–

លក្ខខណ្ឌនៃដំណើរការមហាសន្និបាតមានដូចខាងក្រោម ÷

- ត្រូវធ្វើការផ្សព្វផ្សាយសេចក្តីជូនដំណឹងជាសាធារណៈ និងបិទប្រកាសនៅសាលាឃុំ និង ទីស្នាក់ការសហគមន៍នេសាទ
- ការកោះអញ្ជើញសមាជិកសហគមន៍នេសាទឱ្យចូលរួមមហាសន្និបាតសាមញ្ញ ត្រូវធ្វើឡើងដប់(១០)ថ្ងៃយ៉ាងតិច មុនថ្ងៃបើកមហាសន្និបាត និងបី(៣)ថ្ងៃយ៉ាងតិចមុនថ្ងៃមហាសន្និបាតវិសាមញ្ញ
- មហាសន្និបាតសាមញ្ញ ឬវិសាមញ្ញ អាចប្រជុំពិភាក្សាអនុម័ត និងសម្រេចបានលុះត្រាតែមានវត្តមានលើសពីពាក់កណ្តាលនៃចំនួនសមាជិកសហគមន៍នេសាទ
- អង្គប្រជុំមហាសន្និបាតដឹកនាំដោយប្រធានគណៈកម្មការសហគមន៍នេសាទ ឬប្រធានអង្គប្រជុំដែលជ្រើសរើសដោយការអនុម័តក្នុងចំណោមសមាជិកវត្តមាន
- មហាសន្និបាត ត្រូវអនុម័តលេខាកត់ត្រា ដើម្បីធ្វើកំណត់ហេតុ សេចក្តីសម្រេច និងបញ្ជីវត្តមាន
- លេខាកត់ត្រា និងប្រធានអង្គប្រជុំត្រូវចុះហត្ថលេខាលើកំណត់ហេតុ
- សមាជិកម្នាក់មានសំឡេងតែមួយគត់ ហើយមិនអាចបញ្ជូនមនុស្សមកតំណាងបានទេ
- សេចក្តីសម្រេចរបស់មហាសន្និបាត ត្រូវយកសំឡេងលើសពីពាក់កណ្តាលនៃចំនួនសមាជិកដែលមានវត្តមាន។

ប្រការ ២២.–

មហាសន្និបាតអនុម័ត ÷

- សេចក្តីសម្រេចដូចមានចែងក្នុងប្រការ ១៨ កថាខណ្ឌទី ៣ នៃលក្ខន្តិកៈនេះ
- កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ

៣៩

- ការសុំលាលែង ឬការបណ្តេញចេញពីសមាជិកភាព ឬពីសមាជិកគណៈកម្មការសហគមន៍នេសាទ
- របាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មការសហគមន៍នេសាទ
- គម្រោងចំណូល ចំណាយរបស់សហគមន៍នេសាទ។

## ជំពូកទី ៨

## ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ

ប្រការ ២៣.–

ចំនួនសមាជិកគណៈកម្មការសហគមន៍នេសាទ និង ចំនួនបេក្ខជនឈរឈ្មោះត្រូវអនុម័តដោយមហាសន្និបាត។

ប្រការ ២៤.–

កិច្ចដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ គឺជាភារកិច្ចរបស់គណៈកម្មការរៀបចំការបោះឆ្នោតដែលអនុម័តដោយមហាសន្និបាត។ គណៈកម្មការរៀបចំការបោះឆ្នោតមានសមាសភាពពីបី(៣)ទៅប្រាំ(៥)នាក់ ដែលមានប្រធាន អនុប្រធាន និងសមាជិក តាមការកំណត់ជាក់ស្តែងរបស់មហាសន្និបាត និងត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានចំណេះដឹង និងមានសីលធម៌ល្អ។ គណៈកម្មការរៀបចំការបោះឆ្នោត ត្រូវធ្វើការប្តេជ្ញាចិត្តបង្ហាញពីភាពស្មោះត្រង់។

ប្រការ ២៥.–

គណៈកម្មការរៀបចំការបោះឆ្នោតមានភារកិច្ចដូចខាងក្រោម ÷

- ប្រកាសបេក្ខជនឈរឈ្មោះ
- ណែនាំអំពីនីតិវិធីនៃការបោះឆ្នោត
- បង្ហាញរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ
- រាប់សន្លឹកឆ្នោត និងសរុបលទ្ធផលជូនគណៈអធិបតីដើម្បីប្រកាសជូនមហាសន្និបាតភារកិច្ចរបស់គណៈកម្មការរៀបចំការ បោះឆ្នោតត្រូវបញ្ចប់ដោយស្វ័យប្រវត្តិ បន្ទាប់ពីការប្រកាសលទ្ធផលបោះ ឆ្នោតចប់ជាស្ថាពរ ។

ប្រការ ២៦.–

បេក្ខជនដែលទទួលបានសំឡេងឆ្នោតគាំទ្រច្រើនជាងគេបង្អស់គឺជាប្រធានគណៈកម្មការសហគមន៍នេសាទ។ បេក្ខជនដែលទទួលបានសន្លឹកឆ្នោតបន្តបន្ទាប់ ត្រូវទទួលតួនាទីជាអនុប្រធានជាសមាជិកគណៈកម្មការសហគមន៍នេសាទ តាមលំដាប់លំដោយ។ ក្នុងករណីបេក្ខជនដែលមានសំឡេងគាំទ្រស្មើគ្នា ត្រូវជ្រើសរើសស្ត្រី ឬបោះឆ្នោតរកអ្នកដែលមានសម្លេងគាំទ្រដោយលើកដៃយកមតិលើសពីពាក់កណ្តាលនៃចំនួនសមាជិកសហគមន៍នេសាទដែលចូលរួម។

## ជំពូកទី ៩

## លក្ខខណ្ឌនៃការរំលាយសហគមន៍នេសាទ និង នីតិវិធីដោះស្រាយវិវាទ

### ប្រការ ២៧.–

ការរំលាយសហគមន៍នេសាទត្រូវផ្អែកតាម ៖

- សំណើរបស់ខណ្ឌរដ្ឋបាលជលផល នៅពេលដែលពិនិត្យឃើញថា មានការរំលោភធ្ងន់ធ្ងរលើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- សេចក្តីសម្រេចមហាសន្និបាត
- ក្រោយពីរំលាយសហគមន៍នេសាទ ទ្រព្យសម្បត្តិរបស់សហគមន៍ត្រូវចាត់ចែងតាមការអនុម័តរបស់មហាសន្និបាតលើកលែងតែដែននេសាទដែលត្រូវប្រគល់ជូនរដ្ឋវិញ។

### ប្រការ ២៨.–

ក្នុងករណីមានការតវ៉ាចោទប្រកាន់ថា ដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទមានភាពមិនប្រក្រតី អ្នកតវ៉ាត្រូវបង្ហាញភស្តុតាងឱ្យបានច្បាស់លាស់អំពីភាពមិនប្រក្រតីនោះភ្លាម នៅមុនពេលប្រកាសលទ្ធផលបោះឆ្នោតដើម្បីទុកលទ្ធភាពជូនមហាសន្និបាតពិនិត្យ និងសម្រេច ។

### ប្រការ ២៩.–

វិវាទទាំងឡាយនៅក្នុងសហគមន៍នេសាទ ត្រូវដោះស្រាយដូចខាងក្រោម ៖

- គណៈកម្មការសហគមន៍នេសាទ ត្រូវសម្រុះសម្រួល និងដោះស្រាយរាល់វិវាទដែលកើតមានឡើងនៅក្នុងសហគមន៍នេសាទរបស់ខ្លួន ។

  ក្នុងករណីគណៈកម្មការសហគមន៍នេសាទដោះស្រាយវិវាទនោះពុំបានសម្រេច ត្រូវបញ្ជូនសំណុំរឿងនោះទៅសមត្ថកិច្ចរដ្ឋបាលជលផល ដើម្បីដោះស្រាយទៅតាមឋានានុក្រម ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធតាមការចាំបាច់ ។ ក្នុងករណីដែលបញ្ហាវិវាទនោះនៅតែមិនអាចដោះស្រាយបាន គណៈកម្មការសហគមន៍នេសាទ និង រដ្ឋបាលជលផលត្រូវបញ្ជូនសំណុំរឿងទៅតុលាការខេត្ត ក្រុងសាមីដើម្បីដោះស្រាយតាមផ្លូវច្បាប់។

### ប្រការ ៣០.–

សមាជិកសហគមន៍នេសាទរូបណាដែលមិនគោរពតាមលក្ខន្តិកៈសហគមន៍នេសាទនេះ ត្រូវទទួលទណ្ឌកម្មពីគណៈកម្មការសហគមន៍នេសាទ ឬមហាសន្និបាតសហគមន៍នេសាទ ទៅតាមកម្រិតនៃទោសកំហុសរបស់ខ្លួន។

## ជំពូកទី ១០

## នីតិវិធីនៃការកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

**ប្រការ ៣១ :** ការកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ ត្រូវសម្រេចដោយមហាសន្និបាត។ ការលើកសំណើកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទត្រូវធ្វើឡើងដោយ សមាជិកយ៉ាងតិចមួយ ភាគបី (១/៣) នៃសមាជិកសហគមន៍នេសាទទាំងអស់ ហើយសំណើនេះត្រូវដាក់ជូនគណៈកម្មការសហគមន៍ នេសាទមួយខែមុនបើកមហាសន្និបាត។ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ អាចកែប្រែ បានលុះត្រាតែមានសំឡេងលើសពីពាក់កណ្តាលនៃសមាជិកមហាសន្និបាតសហគមន៍នេសាទ។

## ជំពូកទី ១១

## អវសានប្បញ្ញត្តិ

**ប្រការ ៣២:** លក្ខន្តិកៈសហគមន៍នេសាទនេះ បានអនុម័តដោយមហាសន្និបាតរបស់សហគមន៍នេសាទលើក ទី ២ នៅថ្ងៃទី ០៦ ខែ តុលា ឆ្នាំ២០១០ និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខារបស់ប្រធានគណៈកម្មការសហគមន៍នេសាទ។

ប្រគាបថ្ងៃទី ០៦ ខែ តុលា ឆ្នាំ២០១០

**ប្រធាន គណៈកម្មការសហគមន៍នេសាទ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

# អូរចក

# បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

ដើម្បីធានាការគ្រប់គ្រងសហគមន៍នេសាទឱ្យប្រព្រឹត្តទៅមានប្រសិទ្ធភាព និង មានរបៀបរៀបរយល្អ សហគមន៍
សាទអូរចក សម្រេចដាក់ចេញនូវបទបញ្ជាផ្ទៃក្នុងដូចខាងក្រោម ÷

**ករា ១.–**

គណៈកម្មការ និង សមាជិកសហគមន៍នេសាទគ្រប់រូបត្រូវមានការស្មោះត្រង់ សាមគ្គីឯកភាពផ្ទៃក្នុងជួយស្ថាបនា
មទាំងចូលរួមរៀនសូត្របច្ចេកទេសផ្សេងៗ សម្រាប់បម្រើឱ្យការរីកចម្រើនរបស់សហគមន៍នេសាទ ។

**ករា ២.–**

គណៈកម្មការ សមាជិកសហគមន៍នេសាទ ឬបុគ្គលណាដែលបានកេងប្រវ័ញ្ចធ្វើឱ្យខូចខាត ឬបាត់បង់ទ្រព្យសម្បត្តិ និង
លប្រយោជន៍សហគមន៍នេសាទ ត្រូវទទួលទណ្ឌកម្មដូចខាងក្រោមនេះ ÷

- ចំពោះសមាជិកសហគមន៍នេសាទ ឬ បុគ្គលដទៃទៀតត្រូវសង ឬ ទូទាត់ទៅតាមទំហំនៃការខូចខាតជាក់ស្តែង តាមការសម្រេចរបស់អង្គប្រជុំគណៈកម្មការសហគមន៍នេសាទ។ ក្នុងករណី មិនព្រមសងត្រូវដាក់ជូនមហាសន្និបាតសម្រេច
- ចំពោះគណៈកម្មការសហគមន៍នេសាទត្រូវសង ឬទូទាត់សងការខូចខាតតាមការសម្រេចរបស់មហាសន្និបាត។ ប្រសិនបើនីតិវិធីខាងលើនេះនៅតែមិនអាចដោះស្រាយបាន គឺត្រូវអនុវត្តតាមផ្លូវច្បាប់ និងបទបញ្ជាជាធរមាន។

**ករា ៣ .–**

សមាជិកសហគមន៍នេសាទគ្រប់រូប ត្រូវតែចូលរួមមហាសន្និបាត និងរាល់កិច្ចប្រជុំរបស់សហគមន៍នេសាទ តាមការកោះ
ញើញរបស់ប្រធានគណៈកម្មការសហគមន៍នេសាទ។ ក្នុងករណីដែលសមាជិកសហគមន៍ណាមិនបានមកចូលរួមប្រជុំចំនួន
ដង ជាប់គ្នាដោយគ្មានមូលហេតុច្បាស់លាស់ ត្រូវទទួលការណែនាំពីគណៈកម្មការសហគមន៍នេសាទ។

ករណីនៅតែមិនរាងចាលគណៈកម្មការត្រូវធ្វើសំណើទៅមហាសន្និបាតសម្រេចដើម្បីបញ្ឈប់ពីសមាជិកភាព។

**ករា ៤.–**

សិទ្ធិដាក់ទណ្ឌកម្ម÷

**ក-គណៈកម្មការសហគមន៍នេសាទ**

- អប់រំណែនាំលើកទី១ លើកទី២ និងលើកទី៣
- ព្រមានផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ
- ព្យួរសមាជិកភាពរបស់សមាជិកសហគមន៍នេសាទ

- បញ្ជូនបញ្ហាទំនាស់ទៅមហាសន្និបាតសម្រេច
- ផ្អាកការនេសាទ ធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និង រាយការណ៍ជាបន្ទាន់ទៅសមត្ថកិច្ចរដ្ឋបាលជលផល ចំពោះការនេសាទលើសទំហំ ចំនួន និងខុសប្រភេទ ពេលវេលា ទីតាំងតាមការកំណត់នៅក្នុងផែនការគ្រប់គ្រង និងកិច្ចព្រមព្រៀងនៅក្នុងកន្លែងនេសាទសហគមន៍។

**ខ-មហាសន្និបាត**

- អនុម័តការបណ្តេញចេញដូចមានចែងក្នុងប្រការ ៧ នៃលក្ខន្តិកៈសហគមន៍នេសាទ
- សម្រេចលើសំណងការខូចខាតទ្រព្យសម្បត្តិសហគមន៍នេសាទ
- សម្រេចដាក់ទណ្ឌកម្មដល់គណៈកម្មការ
- ដាក់ទណ្ឌកម្មដល់សមាជិក ឬបុគ្គលដទៃដែលគណៈកម្មការមិនអាចដោះស្រាយបាន។

**ប្រការ ៥.–**

សមាជិកសហគមន៍នេសាទគ្រប់រូបត្រូវរាយការណ៍ជូនគណៈកម្មការសហគមន៍នេសាទអំពីសំភារៈឧបករណ៍នេសាទដែលគ្រួសារនីមួយៗប្រើប្រាស់នៅក្នុងកន្លែងនេសាទសហគមន៍។

**ប្រការ ៦.–**

សមាជិកសហគមន៍នេសាទ អាចប្រើប្រាស់ឧបករណ៍នេសាទជាលក្ខណៈគ្រួសារនៅក្នុងរដូវបើកនេសាទ ដូចមានចែងខាងក្រោម ÷

- មងប្រវែងមិនលើសពី ២០០ម៉ែត្រ ( ពីរយម៉ែត្រ )
- អួនប្រយ៉ុងប្រវែង៣០ម៉ែត្រ ( សាមសិបម៉ែត្រ )
- សន្ទូចរនងមិនលើសពី ៣០០ផ្លែ ( បីរយផ្លែ )
- លបលួងមិនលើសពី ១០លប ( ដប់លប )
- លបត្រីដីរីមិនលើសពី ៥ លប ( ប្រាំលប )
- លាន់មិនលើសពី ៤០លាន់ ( សែសិបលាន់ )
- សន្ទូចបបក់ផ្លែ ១

**ប្រការ ៧.–**

សមាជិកសហគមន៍នេសាទដែល ÷

- ប្រព្រឹត្តផ្ទុយ ឬរារាំងមិនឱ្យសមាជិកដទៃអនុវត្តសិទ្ធិ និង កាតព្វកិច្ចដូចក្នុងប្រការ ៥ នៃលក្ខន្តិកៈ ត្រូវព្យួរសមាជិកភាពដោយគណៈកម្មការសហគមន៍នេសាទ ឬបណ្តេញចេញពីសមាជិកភាពដោយមហាសន្និបាត

- មិនចូលរួមថែរក្សាការពារធនធានជលផលឬមិនរាយការណ៍អំពីសកម្មភាពបទល្មើសជលផលត្រូវព្រមានដោយគណៈកម្មការសហគមន៍នេសាទ ។
- ប្រើប្រាស់ឧបករណ៍ហាមឃាត់ ធ្វើនេសាទខុសច្បាប់ និងកាប់ឆ្ការរានព្រៃលិចទឹក ត្រូវទទួលការផ្តន្ទាទោសតាម ច្បាប់ស្តីពីជលផល ។
- ធ្វើនេសាទក្នុងកន្លែងអភិរក្សរបស់សហគមន៍នេសាទ ត្រូវផ្អាកការនេសាទ ហើយធ្វើកិច្ចសន្យាបញ្ឈប់ ការនេសាទ និងរាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរមូលដ្ឋាន រដ្ឋបាលជលផលមានសមត្ថកិច្ច និងអនុវត្តតាម ច្បាប់ស្តីពីជលផល ។
- អនុវត្តផ្ទុយនឹងបទប្បញ្ញត្តិច្បាប់ស្តីពីជលផល លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កិច្ចព្រមព្រៀង ឬផែនការ គ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវផ្អាកការនេសាទទទួលការព្រមានជាលាយលក្ខណ៍អក្សរធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទនិងរាយការណ៍ជាបន្ទាន់ជូនទៅរដ្ឋបាលជលផលមានសមត្ថកិច្ចដើម្បីដោះស្រាយតាម ច្បាប់ ។

**ប្រការ ៨ :**

ចំពោះអ្នកប្រើប្រាស់ធនធានជលផលដែលមិនមែនជាសមាជិកសហគមន៍នេសាទអាចមានសិទ្ធិចេញចូលនិងនេសាទក្នុងកន្លែងនេសាទសហគមន៍ប៉ុន្តែត្រូវជូនព័ត៌មានដល់គណៈកម្មការសហគមន៍នេសាទនិងបង់ប្រាក់ភាគទានសម្រាប់ការធ្វើនេសាទរយៈពេលមួយរដូវនៅក្នុងកន្លែងនេសាទសហគមន៍ចំនួន៥០ដងនៃប្រាក់បង់ភាគទានប្រចាំឆ្នាំរបស់សមាជិកសហគមន៍នេសាទហើយធ្វើកិច្ចសន្យាគោរពតាមលក្ខន្តិកៈបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទកិច្ចព្រមព្រៀងនិងផែនករគ្រប់គ្រងកន្លែងនេសាទសហគមន៍ ។

ក្នុងករណីដែលអ្នកប្រើប្រាស់ធនធានជលផលដែលមិនមែនជាសមាជិកសហគមន៍នេសាទមិនបានគោរពតាមប្រការនេះគណៈកម្មការសហគមន៍នេសាទមានសិទ្ធិបញ្ឈប់សកម្មភាពនេសាទរបស់ជននោះហើយធ្វើការអប់រំណែនាំនិងអនុវត្តតាមច្បាប់ស្តីពីជលផល ។

**ប្រការ ៩** :បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះត្រូវបានអនុម័តដោយមហាសន្និបាតរបស់សហគមន៍នេសាទ លើកទី ២ . នៅថ្ងៃទី ០៦ ខែតុលា ឆ្នាំ២០១០ និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាដោយប្រធាន គណៈកម្មការសហគមន៍ នេសាទ ។

ប្រគាបថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១០

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

ម៉ៅ គឹមហុង




## តួនាទី និង ភារកិច្ចរបស់គណៈកម្មការសហគមន៍នេសាទអូរចក

**-លោក ម៉ៅ គិមហុង** ប្រធានគណៈកម្មការសហគមន៍នេសាទ ៖

- *ដឹកនាំ និងគ្រប់គ្រងសកម្មភាពការងារសហគមន៍នេសាទទាំងមូល*
- *សម្របសម្រួលប្រជុំរបស់សហគមន៍នេសាទ និងដោះស្រាយបញ្ហាផ្សេងៗដែលកើតមានក្នុងសហគមន៍នេសាទ*
- *ទទួលខុសត្រូវគ្រប់គ្រងផ្នែកហិរញ្ញវត្ថុរបស់សហគមន៍នេសាទ ។*

**-លោក ប៊ុល ហៀច** អនុប្រធាន គណៈកម្មការសហគមន៍នេសាទ ៖

- *បំពេញតួនាទីដឹកនាំ និងទទួលខុសត្រូវការងារជំនួសមុខឱ្យប្រធាននៅពេលប្រធានអវត្តមាន*
- *ទទួលបន្ទុកព័ត៌មានអំពីស្ថានភាពសេដ្ឋកិច្ចរបស់សហគមន៍នេសាទ*
- *ទទួលខុសត្រូវគ្រប់គ្រងផ្នែកការងាររដ្ឋបាលរបស់សហគមន៍នេសាទ*
- *ទទួលភារកិច្ចផ្សេងៗ ដែលប្រធានប្រគល់ជូន ។*

**-លោកស្រី ស្រី កញ្ញា** សមាជិកគណៈកម្មការសហគមន៍នេសាទ ទទួលបន្ទុករដ្ឋបាល និងលេខាធិការ ៖

- *រៀបចំបញ្ជីរាយនាមគណៈកម្មការ និងសមាជិកសហគមន៍នេសាទ*
- *ទទួលពាក្យអ្នកស្ម័គ្រចិត្តសុំចូលជាសមាជិកសហគមន៍នេសាទថ្មី*
- *ធ្វើកំណត់ហេតុ របាយការណ៍ និងបញ្ជីវត្តមានរាល់កិច្ចប្រជុំទាំងអស់*
- *ចងក្រង និងរក្សាទុកឯកសារផ្សេងៗរបស់សហគមន៍នេសាទ ។*

៤- **លោកស្រី ឡើន សួន** សមាជិកគណៈកម្មការសហគមន៍នេសាទ ទទួលបន្ទុកអប់រំ និងផ្សព្វផ្សាយ ៖

- រៀបចំចាត់ចែងឯកសារ សេចក្តីជូនដំណឹង ស្លាកសញ្ញា និងផ្ទាំងរូបភាពផ្សេងៗសម្រាប់ផ្សព្វផ្សាយ
- អប់រំ បណ្តុះបណ្តាល ផ្សព្វផ្សាយលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនការគ្រប់គ្រង និងកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ សេចក្តីសម្រេចនានារបស់មហាសន្និបាតសហគមន៍នេសាទ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធវិស័យជលផល
- ធ្វើរបាយការណ៍អំពីការងារអប់រំ និងផ្សព្វផ្សាយជូនសហគមន៍នេសាទ ។

៥- **លោកស្រី ហឿន ខួច** សមាជិកគណៈកម្មការសហគមន៍នេសាទ ទទួលបន្ទុកអភិវឌ្ឍន៍សហគមន៍ និងស្ថិតិ

- ស្រង់ និងធ្វើស្ថិតិអំពីប្រភេទធនធានជលផល ដែននេសាទ និងឧបករណ៍នេសាទដែលមាននៅក្នុងសហគមន៍នេសាទ
- រៀបចំបញ្ជីសារពើភណ្ឌរបស់សហគមន៍នេសាទ និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- រៀបចំកម្មវិធីនិងគម្រោងផែនការអភិវឌ្ឍន៍សហគមនេសាទ
- តាមដាននិងវាយតំលៃការអនុវត្តរបស់សហគមន៍នេសាទ ។

៦- **លោក ជុំ ម៉េង** សមាជិកគណៈកម្មការសហគមន៍នេសាទ ទទួលបន្ទុកការពារ និងអភិរក្សធនធានជលផល ៖

- ល្បាត ថែរក្សា ការពារធនធានជលផល និងទប់ស្កាត់បទល្មើសជលផលក្នុងកន្លែងនេសាទសហគមន៍
- កសាងផែនការយុទ្ធសាស្ត្រ និងវិធានការការពារធនធានជលផលក្នុងកន្លែងនេសាទសហគមន៍
- រាយការណ៍ ចូលរួមសហការទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើសជលផលនៅក្នុងកន្លែងនេសាទសហគមន៍
- ធ្វើរបាយការណ៍អំពីការងារអភិរក្ស និងបង្ក្រាបរាល់បទល្មើសជលផលជូនសហគមន៍នេសាទ ។

៧- **លោកស្រី សាន ថា** សមាជិកគណៈកម្មការសហគមន៍នេសាទ ទទួលបន្ទុកទំនាក់ទំនង និងសហប្រតិបត្តិការ ៖

- ធ្វើទំនាក់ទំនងដើម្បីកសាងភាពជាដៃគូជាមួយប្រធានភូមិ ក្រុមប្រឹក្សាឃុំ ស្ថាប័នពាក់ព័ន្ធ និងអង្គការនានា
- ស្វែងរកជំនួយឧបត្ថម្ភគាំទ្រផ្នែកបច្ចេកទេស និងផ្នែកហិរញ្ញវត្ថុពីសមត្ថកិច្ចជលផល ស្ថាប័នជំនាញ និងអង្គការជាតិ អន្តរជាតិនានាសម្រាប់អនុវត្តនីដំណើរការសហគមន៍នេសាទ ។

៨- **កញ្ញា សឿន ហុងគាវ** សមាជិកគណៈកម្មការសហគមន៍នេសាទ ទទួលបន្ទុកគណនេយ្យ ៖

- គ្រប់គ្រងគណនី កត់ត្រា និងចុះបញ្ជីថវិកាចំណូល ចំណាយរបស់សហគមន៍នេសាទឱ្យបានត្រឹមត្រូវ
- ចាត់ចែងថវិកាសម្រាប់ធ្វើការចំណាយដោយមានវិក័យបត្រ និងបញ្ជីកត់ត្រាត្រឹមត្រូវ
- រៀបចំគម្រោងផែនការចំណូល ចំណាយរបស់សហគមន៍នេសាទ
- ធ្វើរបាយការណ៍បូកសរុប និងរាយការណ៍អំពីស្ថានភាពចំណូល ចំណាយរបស់សហគមន៍នេសាទប្រចាំខែ ត្រីមាស និងឆ្នាំ
- រក្សាទុករាល់ឯកសារចំណូល ចំណាយរបស់សហគមន៍នេសាទ ។

៩- **លោក ហាំង ហ៊ួយ** សមាជិកគណៈកម្មការសហគមន៍នេសាទ ទទួលបន្ទុកបេឡា ៖

- គ្រប់គ្រង ថែរក្សាសាច់ប្រាក់របស់សហគមន៍នេសាទ និងបើកប្រាក់

- *ធ្វើរបាយការណ៍ផ្ទៀងផ្ទាត់ និងរាយការណ៍អំពីការចំណូល ចំណាយរបស់សហគមន៍នេសាទប្រចាំខែ ត្រីមាស និងឆ្នាំ*
- *រក្សាទុករាល់ឯកសារចំណូល ចំណាយសាច់ប្រាក់របស់សហគមន៍នេសាទ ។*

បានឯកភាពបែងចែកតួនាទី និងភារកិច្ចដោយការស្ម័គ្រចិត្ត

នៅថ្ងៃទី ០៦ ខែ តុលា ឆ្នាំ២០១០

**គណៈកម្មការសហគមន៍នេសាទ**

១-លោក **ម៉ៅ គឹមហុង**

២-លោក **ម៉ិល ហៀច**

៣-លោកស្រី **ស្រី ភញ្ញា**

៤-លោកស្រី **ឡឿន សួន**

៥-លោក ស្រី **ហឿន ទូច**

៦-លោក **ជុំ ម៉ង់**

៧-លោកស្រី **សាន ថា**

៨-កញ្ញា **សឿន ហុងគាង**

៩-លោក **ហ៊ាង ហ៊ុយ**

# សេចក្តីថ្លែងការណ៍នៃការបង្កើតសហគមន៍នេសាទ

# អូរចក

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## សេចក្តីថ្លែងការណ៍
## នៃការបង្កើតសហគមន៍នេសាទ អូរចក

យោងតាមគំនិតផ្តួចផ្តើមដ៏ថ្លៃថ្លារបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជានៅក្នុងក្របខ័ណ្ឌនៃកំណែទម្រង់វិស័យជលផល ទូទាំងប្រទេសចាប់ពីចុងឆ្នាំ២០០០មក និងយោងតាមព្រះរាជាក្រិត្យស្តីពីការបង្កើតសហគមន៍នេសាទ ច្បាប់ស្តីពីជលផល និងអនុក្រិត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងភូមិ**ប្រគាបឃុំម្សាក្រងស្រុកស្ទោង**បានស្ម័គ្រចិត្តរួមគ្នាបង្កើតជាសហគមន៍នេសាទដើម្បីចូលរួមសហការជាមួយអាជ្ញាធរភូមិឃុំនិងរដ្ឋបាលជលផលក្នុងការថែរក្សាការពារគ្រប់គ្រងធនធានធម្មជាតិនិងទប់ស្កាត់រាល់បទល្មើសជលផលនៅក្នុងកន្លែងនេសាទសហគមន៍ព្រមទាំងធានាឱ្យសមាជិកសហគមន៍នេសាទទាំងអស់មានសិទ្ធិស្មើគ្នាលើការប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាពនិងមានបំណងលើកស្ទួយកម្រិតជីវភាពរស់នៅឱ្យកាន់តែប្រសើរឡើងដូចបានចែងក្នុងលក្ខន្តិកៈបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទកិច្ចព្រមព្រៀងនិងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ។ដោយសារមានការជួយសម្របសម្រួលពីខណ្ឌរដ្ឋបាលជលផលកំពង់ធំនិងអាជ្ញាធរភូមិនិងក្រុមប្រឹក្សាឃុំ**ម្សាក្រង**សហគមន៍បានរៀបចំបើកមហាសន្និបាតលើកទី ២ នៅថ្ងៃទី**០៦** ខែ**តុលា** ឆ្នាំ**២០១០** ដែលមានអ្នកចូលរួមចំនួន **២២៤**នាក់ ក្នុង នោះមានស្រី **១០៦**នាក់ដើម្បីអនុម័តសមាជិកសហគមន៍នេសាទពេញសិទ្ធិអនុម័តបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទចំនួន**០៩**រូបក្នុងនោះម៉ានស្រី**០៥**រូបសម្រាប់ដឹកនាំសហគមន៍នេសាទដែលមានកន្លែងនេសាទសហគមន៍មានទំហំផ្ទៃក្រឡាចំនួន **១៩៥**ហិកតា ។

បន្ទាប់ពីបានទទួលស្គាល់សហគមន៍នេសាទយើងខ្ញុំតាមរយៈមហាសន្និបាតលើកទី២មក ខ្ញុំបាទជាប្រធានគណៈកម្មការសហគមន៍នេសាទ ដែលជាតំណាងឱ្យសមាជិកសមាជិកាសហគមន៍ទាំងអស់សូមសន្យាថា និងខិតខំដឹកនាំគ្រប់គ្រងសហគមន៍នេសាទឱ្យបានល្អដោយប្រកាន់ភ្ជាប់នូវភាពស្មោះត្រង់ សាមគ្គីឯកភាពផ្ទៃក្នុង ជួយស្ថាបនា និងចូលរួមគ្រប់គ្រង អភិរក្ស អភិវឌ្ឍ ប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព ស្របតាមលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនិងវិស័យជល-ផល ព្រមទាំងខិតខំរៀនសូត្រ កសាងទំនាក់ទំនងជាមួយគ្រប់អង្គភាពស្ថាប័នរដ្ឋ អង្គការនានា ដើម្បីស្វែងរកអ្នកជួយឧបត្ថម្ភគាំទ្របច្ចេកទេស និងថវិកាសម្រាប់ដំណើរការរីកចំរើនរបស់សហគមន៍នេសាទ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមលោកនាយខណ្ឌរដ្ឋបាលជលផលកំពង់ធំមេត្តាពិនិត្យ និងសម្រេចដើម្បីសុំចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ **អូរចក** ដោយអនុគ្រោះ ។

ធ្វើនៅភូមិប្រគាប ថ្ងៃទី០៤.ខែ.១១.ឆ្នាំ ២០១០

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

# លិខិតស្នើសុំចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍

## អូចក

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ប្រធានគណៈកម្មការសហគមន៍នេសាទអូរចក**

**សូមគោរពជូន**

**លោកនាយខណ្ឌរដ្ឋបាលជលផលកំពង់ធំ**

**កម្មវត្ថុ:** សំណើសុំចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ **អូរចក** ។

**យោង :** អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៧ ។

-សេចក្តីសម្រេចរបស់មហាសន្និបាតសហគមន៍នេសាទលើក ទី ២ ដែលបានប្រារព្ធធ្វើឡើងនៅថ្ងៃទី **០៦ ខែ តុលា ឆ្នាំ២០១០ ។**

**លិខិតភ្ជាប់:** កម្មវិធីចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ **អូរចក**

សេចក្តីដូចមានចែងនៅក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូនលោកនាយមេត្តាជ្រាបថា សហគមន៍នេសាទ **អូរចក** បានបង្កើតឡើងដោយការស្ម័គ្រចិត្ត និងមានគំនិតផ្តួចផ្តើមបង្កើនជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងភូមិ **ប្រគាបឃុំម្សាក្រង**ស្រុក**ស្ទោង**និងមានការជួយសម្របសម្រួលពីខណ្ឌរដ្ឋបាលជលផលកំពង់ធំអាជ្ញាធរភូមិនិងក្រុមប្រឹក្សាឃុំ **ម្សាក្រង**សហគមន៍នេសាទមានគណៈកម្មការសហគមន៍នេសាទចំនួន**០៩**រូបក្នុងនោះមានស្ត្រី**៥**រូបនិងមានសមាជិកសហគមនសរុបចំនួន**៣៧៣**នាក់ស្រីចំនួន**១៨៤**នាក់ ។បន្ទាប់ពីបានបង្កើតរួចមកសហគមន៍នេសាទបានដឹកនាំនិងចូលរួមអនុវត្តដំណើរការសហគមន៍យ៉ាងសកម្មជាមួយនិងការចូលរួមឧត្តម្ភគាំទ្រពីសមត្ថកិច្ចរដ្ឋបាលជលផល និងអាជ្ញាធរភូមិឃុំ ។ ម្យ៉ាងទៀត គណៈកម្មការសហគមន៍នេសាទបានរៀបចំបញ្ជីឈ្មោះសមាជិកសហគមន៍នេសាទលក្ខន្តិកៈបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទផែនទីនិងកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍រួចជាស្រេចហើយនិងគ្រោងរៀបចំកម្មវីធីចុះកិច្ចព្រមព្រៀងសហគមននេសាទជាមួយលោកនាយខណ្ឌរដ្ឋបាលជលផលកំពង់ធំដែលនឹងប្រព្រឹត្តធ្វើ

ឡើងនាថ្ងៃទី.០២.ខែ.....ធ្នូ..........ឆ្នាំ២០១០

សូមជូនភ្ជាប់មកជាមួយនូវ :

១-កិច្ចព្រមព្រៀងសហគមន៍នេសាទកន្លែងនេសាទសហគមន៍ ។

២-ផែនទីកន្លែងនេសាទសហគមន៍មាត្រដ្ឋាន ១/៥០,០០០ ។

៣-បញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ និងគណៈកម្មការសហគមន៍នេសាទ ។

៤- លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ ។

៥-សេចក្តីថ្លែងការណ៍នៃការបង្កើតសហគមន៍នេសាទ។

អាស្រ័យហេតុនេះ សូមលោកនាយមេត្តាពិនិត្យ និងសម្រេចដោយអនុគ្រោះ ។

ធ្វើនៅភូមិគ្រាប ថ្ងៃទី.០៥.....ខែ..11.......ឆ្នាំ២០១០

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

# ឯកសារផ្សេងៗ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៦២៩ ប្រក.កសក

# ប្រកាស

## ស្តីពី

## ការចុះបញ្ជីសហគមន៍នេសាទចំនួន ៥៧ នៅខេត្តកំពង់ធំ កោះកុង ព្រះសីហនុ ក្រចេះ រតនគីរី និងខេត្តស្ទឹងត្រែង

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៤០ ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការបង្កើតសហគមន៍នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៅស៊ូ... ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និង ការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ
- បានឃើញប្រកាសលេខ ៦៨១ ប្រក.កសក.ប ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ និងមន្ទីរពិសោធន៍ចំណុះនាយកដ្ឋាន និងវិទ្យាស្ថាន ក្រោមឱវាទរដ្ឋបាលជលផល
- បានឃើញប្រកាសលេខ ៣១៦ ប្រក.កសក ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ

- យោងតាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា ប្រធានរដ្ឋបាលជលផល

## សម្រេច

**ប្រការ ១.-**

ត្រូវបានចុះបញ្ជីជាផ្លូវការ និងទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនូវសហគមន៍នេសាទ ចំនួន ៥៧ រួមមាន៖ ខេត្តកំពង់ធំចំនួន ០១ សហគមន៍ កោះកុងចំនួន ០២ សហគមន៍ ព្រះសីហនុចំនួន ០១ សហគមន៍ ក្រចេះចំនួន ១៤ សហគមន៍ រតនគីរីចំនួន ០៤ សហគមន៍ និងខេត្តស្ទឹងត្រែងចំនួន ៣៥ សហគមន៍ ដែលមានឈ្មោះសហគមន៍នេសាទ ចំនួនសមាជិក ចំនួនគណៈកម្មការ ទំហំកន្លែងនេសាទសហគមន៍ ឈ្មោះភូមិ ឃុំ ស្រុក ខេត្ត និងនិយាមកាជាចំណុចគោលនៃព្រំប្រទល់កន្លែងនេសាទសហគមន៍ ដូចមាននៅក្នុងតារាង និងផែនទីកន្លែងនេសាទសហគមន៍នីមួយៗ ជាឧបសម្ព័ន្ធភ្ជាប់ប្រកាសនេះ ។

**ប្រការ ២.-**

ព្រំប្រទល់កន្លែងនេសាទសហគមន៍នីមួយៗ ដែលបានកំណត់ក្នុងផែនទី ដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវបានទទួលស្គាល់ដោយនាយខណ្ឌរដ្ឋបាលជលផល អាជ្ញាធរដែនដី ប្រធានរដ្ឋបាលជលផល និង រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

**ប្រការ ៣.-**

ទំហំកន្លែងនេសាទសហគមន៍ និយាមកាជាចំណុចគោលនៃព្រំប្រទល់កន្លែងនេសាទសហគមន៍ ចំនួនភូមិ និងទីតាំងភូមិសាស្ត្ររបស់សហគមន៍ ដូចមានចែងក្នុងប្រការ ១ អាចកែប្រែបានតាមការចាំបាច់ដោយប្រកាសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ ៤.-**

ប្រកាស ឬសេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥.-**

អគ្គលេខាធិការ អគ្គាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលជលផល ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានមន្ទីរកសិកម្មខេត្តពាក់ព័ន្ធ និងប្រធានសហគមន៍នេសាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ៥ ឆ្នាំ ២០១១

**រដ្ឋមន្ត្រី**

**ចាន់ សារុន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- សាលាខេត្តពាក់ព័ន្ធ
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធ:** ភ្ជាប់ប្រកាសលេខ...៦២៨ ជ.ក.ន.ស.ស...ចុះថ្ងៃទី...២៦.....ខែ....ធ្នូ............ឆ្នាំ ២០១១

# សហគមន៍នេសាទក្នុងខេត្តកំពង់ធំ កោះកុង ព្រះសីហនុ ក្រចេះ រតនគិរី និងខេត្តស្ទឹងត្រែង

| ល.រ | ឈ្មោះសហគមន៍នេសាទ | ចំនួនសមាជិក | ចំនួនគណៈកម្មការសហគមន៍ | ទំហំផ្ទៃសហគមន៍ (ហិកតា) | ភូមិ | ឃុំ/សង្កាត់ | ស្រុក/ក្រុង | Projection :UTM, Everest 1830, Datum : Indian 1960, Zone : 48 N (X,Y) | (X,Y) |
|---|---|---|---|---|---|---|---|---|---|
| **១-ខេត្តកំពង់ធំ** | | | | | | | | | |
| ១ | អូរចក | ៣៧៣ | ៩ | ១៩៥ | ប្រគាប | ម្សាក្រង | ស្ទោង | A. (400522, 1434073)<br>B. (400732, 1434319)<br>C. (441097, 1434309) | D. (441467, 1434034)<br>E.( 441501, 1433471)<br>F.(441048, 1432437) |
| **២-ខេត្តកោះកុង** | | | | | | | | | |
| ១ | ថ្មស | ៦០០ | ១១ | ១១.២២០ | ស្រែថ្មី | ថ្មស | បូទុមសាគរ | A. (327674, 1204371)<br>B. (328009, 1204381)<br>C. (328148, 1204455) | D. (327750, 1214899)<br>E. (327499, 1214857)<br>F. (326967, 1214963) |
| ២ | តាមាឃ | ២៧៨ | ៩ | ៩.៣៩៤ | តាមាឃ | អណ្ដូងទឹក | បូទុមសាគរ | A. (327698, 1225937)<br>B. (327844, 1225858)<br>C. (329482, 1226786) | D. (332088, 1225277)<br>E. (331005, 1224455)<br>F. (330614, 1221613) |
| **៣-ខេត្តព្រះសីហនុ** | | | | | | | | | |
| ១ | ភូមិដើមថ្កូវ | ១០១ | ៧ | ១.៧៣៤ | ដើមថ្កូវ | កោះរ៉ុង | ព្រះសីហនុ | A. (310314, 1185796)<br>B. (310812, 1184875)<br>C. (311316, 1185599) | D. (312674, 1185761)<br>E. (314113, 1184304)<br>F. (314010, 1183153) |
| **៤-ខេត្តក្រចេះ** | | | | | | | | | |
| ១ | តំរ៉ែ | ៦៣ | ៩ | ១៨៩ | តំរ៉ែ | បឹងចារ | សំបូរ | A. (605399, 1419573)<br>B. (604157, 1414212)<br>C. (604533, 1413852) | D.(605623, 1417477)<br>E.(605489, 1417597)<br>F.(606116, 1420929) |
| ២ | កំពង់រទេះ | ១២៣ | ៩ | ៥២៧ | កំពង់រទេះ | បឹងចារ | សំបូរ | A. (607190, 1422165)<br>B. (607497, 1422004)<br>C. (608815, 1425885) | D.(609021, 1426592)<br>E.(609671, 1427748)<br>F.(610630, 1431309) |
| ៣ | កោះដំបង | ៦៤ | ៩ | ១៤៧ | កោះដំបង | បឹងចារ | សំបូរ | A. (605623, 1417477)<br>B. (605489, 1417597)<br>C. (607147, 1419977) | D.(607497, 1422004)<br>E.(607190, 1422165) |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៤ | កោះខ្មែរ | ១៥១ | ៩ | ១.៣០៧ | កោះខ្មែរ | អូរគ្រៀង | សំបូរ | A. (615258, 1446806)<br>B. (614436, 1447893)<br>C. (614093, 1449430) | D.(614691, 1451371)<br>E.(616018, 1454750)<br>F.(613955, 1457042) |
| ៥ | ពន្ធជា | ១០៦ | ៩ | ៨៤៩ | ពន្ធជា | អូរគ្រៀង | សំបូរ | A. (614359, 1445082)<br>B. (613833, 1441798)<br>C. (612421, 1440150) | D.(616393, 1441445)<br>E.(616444, 1442529)<br>F.(616965, 1444159) |
| ៦ | ខ្សាច់លាវ | ៧១ | ៩ | ៨៥៣ | ខ្សាច់លាវ | អូរគ្រៀង | សំបូរ | A. (609013, 1442917)<br>B. (608940, 1443519)<br>C. (609513, 1443718) | D.(610722, 1449090)<br>E.(610710, 1450902)<br>F.(611617, 1451269) |
| ៧ | វឌ្ឍនៈ | ២៨១ | ៧ | ៦៨០ | វឌ្ឍនៈ | វឌ្ឍនៈ | សំបូរ | A.( 609664, 1401649)<br>B.( 609142, 1403071)<br>C.( 608292, 1405124) | D.(607119, 1402510)<br>F.(607713, 1401471)<br>G.(607840, 1401114) |
| ៨ | ព្រែកគ្រៀង | ២៦០ | ៩ | ១.០៤០ | ព្រែកគ្រៀង | វឌ្ឍនៈ | សំបូរ | A.(609271,1395440)<br>B.( 609179,1396291)<br>C.( 609261,1398638) | D.( 08461,1399168)<br>E.( 607325,1395710)<br>F.( 606898,1395666) |
| ៩ | អន្លង់ព្រះគោ | ២៥៤ | ៧ | ៣៥១ | អន្លង់ព្រះគោ | វឌ្ឍនៈ | សំបូរ | A.(609261, 1398638)<br>B.(609649, 1401021)<br>C.(609664, 1401649) | D(607840, 1401114)<br>E(608188, 1400187)<br>F(608461, 1399168) |
| ១០ | ព្រែកសាម៉ាន់ | ៥២៨ | ១១ | ១.២៧៤ | ព្រែកសាម៉ាន់ | ព្រែកសាម៉ាន់ | ឆ្លូង | A.(613059, 1359202)<br>B.(614675, 1358013)<br>C.(614811, 1357943) | D.(612355, 1355360)<br>E.(608087, 1352643)<br>F.(611319, 1356851) |
| ១១ | ភូមិថ្មី | ៣១៥ | ១១ | ១.៤៤១ | ភូមិថ្មី | ខ្សាច់អណ្ដែត | ឆ្លូង | A.(591595, 1353732)<br>B.(591688, 1350412)<br>C.(592708, 1349404) | D.(593610, 1351021)<br>E.(594727, 1351680)<br>F(594502, 1352909) |
| ១២ | សោបលើ | ៣៩០ | ១១ | ៨២៦ | សោបលើ | សោប | ព្រែកប្រសព្វ | A.(606790, 1381869)<br>B.(607193, 1481194)<br>C.(608946, 1379088) | D.(607980, 1378497)<br>E.(605767, 1378522)<br>F.(605983, 1379090) |
| ១៣ | ព្រែករកា | ២៧៩ | ១១ | ៥៩៥ | ព្រែករកា | សោប | ព្រែកប្រសព្វ | A.(608975, 1378965)<br>B.(608192, 1378760)<br>C.(607747, 1378305) | D.(607309, 1377487)<br>E.(609776, 1378242)<br>F.(600692, 1376405) |
| ១៤ | ព្រែកជីក | ៣៨៧ | ៩ | ២.៩៦៤ | ព្រែកជីក | សោប | ព្រែកប្រសព្វ | A(606814, 1383561)<br>B(606965, 1381886)<br>C(603401, 1384434) | D(605027, 1384184)<br>E(602484, 1388029)<br>F(601334, 1384356) |
| **៥-ខេត្តរតនគិរី** | | | | | | | | | |
| ១ | កោះប៉ង | ២២៧ | ៥ | ៣៧៧,៣៨ | ប៉ាហាយ ប៉ាតិង និងឡាំអាវ | កោះប៉ង | វើនសៃ | A. (709862, 1552609)<br>B. (711990, 1553335)<br>C. (712350, 1552743) | D.(717599, 1552765)<br>E.(717585, 1553126)<br>F.(715998, 1553953) |
| ២ | កោះពាក្យ | ២០៧ | ៥ | ៣២១,៧១ | យួន ផាត់ណាម និងកោះពាក្យ | កោះពាក្យ | វើនសៃ | A. (707008, 1547552)<br>B. (706396, 1549831)<br>C. (707336, 1551432) | D.(706687, 1551577)<br>E.(705973, 1549871)<br>F.(706423, 1547212) |
| ៣ | កាចូនកុកឡាក់ | ៣០០ | ៥ | ៣៣៣ | ឡាមីយ កាលឹម | កាចូន និង | វើនសៃ | A. (699987, 1545090)<br>B. (700685, 1545381) | D.(705906, 1545695)<br>E.(706330, 1546172) |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | ទៀមលើ និង<br>កាចូនក្រោម | កុកឡាក់ | | C. (700965, 1546084) | F.(705906, 1546423) |
| ៤ | ប៉ុងរើនសែ | ២៦៣ | ៥ | ៤៦៩,១៨ | បានហ្វាំង<br>បានប៉ុង រើនសែ<br>និងកាឡាន់ | ប៉ុង និង<br>រើនសែ | រើនសែ | A. (691970, 1542502)<br>B. (691975, 1542416)<br>C. (692472, 1542062) | D.(700256, 1544989)<br>E.(700770, 1545463)<br>F.(700477, 1545645) |
| **៦-ខេត្តស្ទឹងត្រែង** | | | | | | | | | |
| ១ | ស្វាយ | ២១៥ | ៧ | ១.២៦៨ | ស្វាយ | កោះស្រឡាយ | សៀមបូក | A. (600477, 1478037)<br>B. (601240, 1478083)<br>C. (601863, 1477787) | D.(601523, 1483759)<br>E.(601743, 1486821)<br>F.(600799, 1488807) |
| ២ | ភ្លុល | ១១២ | ៧ | ៦៦៨ | ភ្លុល | កោះស្រឡាយ | សៀមបូក | A. (599945, 1473767)<br>B. (600642, 1473580)<br>C. (601188, 1474246) | D.(601863, 1477787)<br>E.(601240, 1478083)<br>F.(600477, 1478037) |
| ៣ | កោះសំពាយ | ៥១៥ | ៧ | ១.០៥៦ | កោះសំពាយ | កោះសំពាយ | សៀមបូក | A. (601904, 1480544)<br>B. (601760, 1481015)<br>C. (601843, 1481518) | D.(603514, 1484956)<br>E.(603395, 1485639)<br>F.(603088, 1486953) |
| ៤ | ត្បូងខ្លា | ១៥១ | ៧ | ៦៣២ | ត្បូងខ្លា | អូរម្រះ | សៀមបូក | A. (607421, 1463775)<br>B. (606849, 1464038)<br>C. (606046, 1464329) | D.(605757, 1466506)<br>E.(605944, 1466984)<br>F.(605791, 1467904) |
| ៥ | កោះព្រះ | ៥៩៨ | ៧ | ១.៣៥១ | កោះព្រះ | កោះព្រះ | សៀមបូក | A. (604964, 1469459)<br>B. (605181, 1465892)<br>C. (604722, 1465116) | D.(601177, 1468268)<br>E.(601083, 1468933)<br>F.(600914, 1469630) |
| ៦ | ដំរីផុង | ១៩៧ | ៧ | ៣២៥ | ដំរីផុង | កោះសំពាយ | សៀមបូក | A. (603822, 1478460)<br>B. (602763, 1479497)<br>C. (602209, 1480064) | D.(601465, 1479351)<br>E.(601680, 1478503)<br>F.(602676, 1478834) |
| ៧ | ស្រែក្រសាំង | ៣៦៨ | ៧ | ៧០០ | ស្រែក្រសាំង | ស្រែក្រសាំង | សៀមបូក | A. (604795, 1471829)<br>B. (604006, 1471806)<br>C. (604321, 1470597) | D.(605450, 1473942)<br>E.(604710, 1476241)<br>F.(603892, 1477631) |
| ៨ | កោះក្រូច | ១៤៧ | ៧ | ៥៧៩ | កោះក្រូច | ស្រែក្រសាំង | សៀមបូក | A. (604795, 1471829)<br>B. (604653, 1472708)<br>C. (604353, 1473452) | D.(602751, 1477994)<br>E.(602677, 1478838)<br>F.(601680, 1478503) |
| ៩ | សៀមបូក | ១៩៧ | ៧ | ១៨១ | សៀមបូក | សៀមបូក | សៀមបូក | A. (600525, 1467026)<br>B. (601158, 1467062)<br>C. (601175, 1467824) | D.(600914, 1469630)<br>E.(600480, 1469550)<br>F.(600485, 1469118) |
| ១០ | អូរឡង់ | ១១៤ | ៧ | ៨៩០ | អូរឡង់ | សៀមបូក | សៀមបូក | A. (605040, 1458572)<br>B. (603294, 1461301)<br>C. (603073, 1462136) | D.(600548, 1467020)<br>E.(601158, 1467062)<br>F.(602267, 1465160) |
| ១១ | ទន្សោង | ៧៨ | ៧ | ៤៣៧ | ទន្សោង | សៀមបូក | សៀមបូក | A. (600480, 1469550)<br>B. (600914, 1469630)<br>C. (600773, 1470396) | D.(600642, 1473580)<br>E.(599945, 1473767)<br>F.(599707, 1473183) |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១២ | អូរច្រឡង់ | ១០៥ | ៧ | ២៩៩ | អូរច្រឡង់ | អូរម្រះ | សៀមបូក | A. (609106, 1462434)<br>B. (609669, 1462021)<br>C. (610102, 1461958) | D.(609341, 1460739)<br>E.(607996, 1461522)<br>F.(608820, 1462233) |
| ១៣ | កោះជ្រឹម | ១៨៩ | ៧ | ៤២៥ | កោះជ្រឹម | អូរម្រះ | សៀមបូក | A.( 603863, 1465840)<br>B.( 604722, 1465116)<br>C.( 605577, 1463213) | D.( 605069, 1462192)<br>E.( 605006, 1462241)<br>F.( 602828, 1464206) |
| ១៤ | អូរម្រះ | ៦២ | ៧ | ៣០១ | អូរម្រះ | អូរម្រះ | សៀមបូក | A.( 607422, 1463776)<br>B.( 608308, 1463074)<br>C.( 609019, 1462505) | D.( 608820, 1462233)<br>E.( 607996, 1461522)<br>F.( 606538, 1462246) |
| ១៥ | កំពង់ប៉ាង | ១៣២ | ៧ | ១៩៤ | កំពង់ប៉ាង | កាំងចាម | សៀមបូក | A.( 593748, 1478539)<br>B.( 593415, 1479705)<br>C.( 593460, 1480668) | D.( 593984, 1481659)<br>E.( 594891, 1477345)<br>F.( 594724, 1477944) |
| ១៦ | កោះស្រឡៅ | ២៤១ | ១១ | ១.៦៨៧ | កោះស្រឡៅ | កោះស្នែង | ថាឡាបរិវ៉ាត់ | A.( 611262, 1508884)<br>B.( 611262, 1508884)<br>C.( 609877, 1505983) | D.( 609490, 1504133)<br>E.( 611343, 1506274)<br>F.( 612133, 1506154) |
| ១៧ | កោះកី | ១៧២ | ៧ | ៤០៨ | កោះកី | កោះស្នែង | ថាឡាបរិវ៉ាត់ | A.( 610424, 1515318)<br>B.( 609730, 1516047)<br>C.( 610510, 1516652) | D.( 609735, 1517406)<br>E.( 609494, 1518643)<br>F.( 609028, 1518362) |
| ១៨ | កោះកន្ទាយ | ៣៨០ | ១១ | ១.១៩៥ | ជាំធំ | កោះស្នែង | ថាឡាបរិវ៉ាត់ | A.( 609275, 1515646)<br>B.( 607783, 1518121)<br>C.( 605372, 1519395) | D.( 603721, 1522897)<br>E.( 603102, 1523711)<br>F.( 602063, 15242449) |
| ១៩ | កោះស្នែង | ៣៨០ | ១១ | ២.៤៨០ | កោះស្នែង | កោះស្នែង | ថាឡាបរិវ៉ាត់ | A.( 612043, 1512276)<br>B.( 614091, 1511417)<br>C.( 612036, 1513991) | D.( 611162, 1510667)<br>E.( 610405, 1510656)<br>F. (611226, 1509369) |
| ២០ | កោះល្វ | ១១៧ | ៧ | ៥០៨ | កោះល្វ | ព្រះរំកិល | ថាឡាបរិវ៉ាត់ | A.( 604445, 1539231)<br>B.( 604052, 1539138)<br>C.( 603720, 1540045) | D.( 606500, 1538849)<br>E.( 606620, 1538086)<br>F. (606653, 1537682) |
| ២១ | កោះឈើទាលតូច | ២៩៨ | ៩ | ៤៦៤ | កោះឈើ ទាលតូច | ព្រះរំកិល | ថាឡាបរិវ៉ាត់ | A.( 606286, 1534595)<br>B.( 607078, 1535778)<br>C.( 605895, 1535832) | D.( 608074, 1534308)<br>E.( 607920, 1534065)<br>E. (607722, 1533623) |
| ២២ | ក្រឡាពាស | ៣២៧ | ៧ | ២.៤២៥ | ក្រឡាពាស | ព្រះរំកិល | ថាឡាបរិវ៉ាត់ | A.( 605271, 1533870)<br>B.( 604991, 1534660)<br>C.( 605187, 1534846) | D.( 605718, 1529825)<br>E.( 604370, 1526888)<br>F. (604318, 1525152) |
| ២៣ | កោះឈើទាលធំ | ១៩៦ | ៩ | ៣២៩ | កោះឈើទាល ធំ | ព្រះរំកិល | ថាឡាបរិវ៉ាត់ | A.( 606194, 1539245)<br>B.( 606500, 1538849)<br>C.( 606620, 1538086) | D.( 607998, 1537889)<br>E.( 607989, 1537449)<br>F. (607846, 1537324) |
| ២៤ | កោះហិប | ១៩២ | ១១ | ១.១២៩ | កោះហិប | អូរស្វាយ | ថាឡាបរិវ៉ាត់ | A.( 606171, 1519704)<br>B.( 604917, 1521500)<br>C.( 606562, 1521457) | D.( 609028, 1518362)<br>E.( 607783, 1518121)<br>F.( 605372, 1519395) |
| ២៥ | កោះញ្ញៅ | ២០៥ | ៩ | ៥១៤ | កោះញ្ញៅ | អូរស្វាយ | ថាឡាបរិវ៉ាត់ | A.( 608597, 1536229)<br>B.( 607989, 1539449)<br>C.( 607846, 1537324) | D.( 607896, 1534624)<br>E.( 608074, 1534308)<br>F.( 608927, 1535559) |
| ២៦ | អូររុន | ២៤១ | ៧ | ១.៣៦៣ | អូររុន | អូរស្វាយ | ថាឡាបរិវ៉ាត់ | A.( 606478, 1531194)<br>B.( 608428, 1533298)<br>C.( 606075, 1529486) | D.( 605961, 1527073)<br>E.( 606233, 1528189)<br>F. (606020, 1528587) |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ២៧ | អូរស្វាយ | ២២៣ | ៧ | ៣១១ | អូរស្វាយ | អូរស្វាយ | ថាឡាបរិវ៉ាត់ | A.( 608380, 1533967)<br>B.( 607453, 1539191)<br>C.( 607810, 1539082) | D.( 607989, 1539449)<br>E.( 607896, 1534624)<br>F. (608996, 1535470) |
| ២៨ | វើនសៀន | ១៦៣ | ៧ | ១.៣៦៣ | វើនសៀន | អូរស្វាយ | ថាឡាបរិវ៉ាត់ | A.( 606476, 1523170)<br>B.( 604917, 1521500)<br>C.( 606562, 1521457) | D.( 608809, 1519632)<br>E.( 604318, 1525152)<br>F.( 605062, 1524147) |
| ២៩ | ថ្មតាគុ | ១១៤ | ៧ | ៤៥៤ | ខាំផាន់ | សាមគ្គី | ស្ទឹងត្រែង | A.( 615557, 1503932)<br>B.( 611501, 1503967)<br>C.( 611877, 1503576) | D.( 611686, 1505284)<br>E.( 611623, 1503934) |
| ៣០ | ថ្មី | ៣៤២ | ៩ | ៣២៣ | ថ្មី | សាមគ្គី | ស្ទឹងត្រែង | A.( 608787, 1501219)<br>B.( 610268, 1502746)<br>C.( 609460, 1503772) | D.( 609247, 1504125)<br>E.( 609073, 1504322)<br>F.( 608886, 1503497) |
| ៣១ | អន្លង់ថ្មបាំង | ១៥៨ | ៧ | ១.២៩៩ | ឃេ | សាមគ្គី | ស្ទឹងត្រែង | A.( 614114, 1511081)<br>B.( 613698, 1511749)<br>C.( 613533, 1511787) | D.( 613048, 1507497)<br>E.( 613287, 1507228)<br>F. (612205, 1506167) |
| ៣២ | អន្លង់កោះកាង | ២៨៧ | ៧ | ៧៧៦ | កោះខនឌិន | សាមគ្គី | ស្ទឹងត្រែង | A.( 611547, 1503803)<br>B.( 611312, 1503621)<br>C.( 611099, 1503582) | D.( 610728, 1503491)<br>E.( 610281, 1503287)<br>F.( 609786, 1502911) |
| ៣៣ | ស្រែគរមានជ័យ | ៥៦៥ | ៧ | ១.៦៦៧ | ស្រែគរ១ និង ស្រែគរ២ | ស្រែគរ | សេសាន | A.( 654681, 1512536)<br>B.( 654800, 1512177)<br>C.( 654490, 1511787) | D.( 639356, 1503048)<br>E.( 638958, 1499300)<br>F. (638536, 1499414) |
| ៣៤ | ភ្លុកមានជ័យ | ៣៦២ | ៧ | ១.០១៨ | បានប៊ុង និង ភ្លុក | ភ្លុក | សេសាន | A.( 622019, 1499797)<br>B.( 623025, 1499651)<br>C.( 623146, 1499622) | D.( 622969, 1499218)<br>E.( 623649, 1499881)<br>F. (624533, 1500167) |
| ៣៥ | ផ្លូវតាម៉ៅ | ៥១១ | ៧ | ៥០៥ | កំភុន បានម៉ៃ និងសេសាន | កំភុន | សេសាន | A.( 617219, 1498154)<br>B.( 616020, 1497545)<br>C.( 614872, 1496732) | D.( 618272, 1499340)<br>E.( 618468, 1499443)<br>F. (618611, 1499486) |

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
ប្រធានរដ្ឋបាលជលផល

ពៅ ធួក